**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

U.S. Embassy Phnom Penh

# សេចក្ដីប្រកាសព័ត៌មានរួម
# រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសហរដ្ឋអាមេរិក
# ស្ដីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យសុខាភិបាល
# លើអនុស្សារណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងចែករំលែកទិន្នន័យ

នាថ្ងៃព្រហស្បតិ៍ ១៥កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី០២ ខែមេសា ឆ្នាំ២០២៦, តំណាងរាជរដ្ឋាភិបាលកម្ពុជា **ឯកឧត្តម ឈៀង យ៉ាណារ៉ា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស អនុប្រធានទី២ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង **ឯកឧត្តមសាស្ត្រាចារ្យ ឈាង រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នា (Memorandum of Understanding) ស្ដីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យសុខាភិបាល និងកិច្ចព្រមព្រៀងស្ដីពីការចែករំលែកទិន្នន័យ (Data Sharing Agreement) ជាមួយ **លោកស្រី Bridgette L. Walker** ភារៈធារីនៃស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា ។

អនុស្សារណៈនៃការយោគយល់គ្នានេះ បានបង្កើតនូវក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយដើម្បីពង្រឹងភាពជាដៃគូទ្វេភាគីក្នុងវិស័យសុខាភិបាល, រួមចំណែកក្នុងការលើកកម្ពស់សុខភាពសាធារណៈ និងសុខុមាលភាពរបស់ប្រជាជន ។ តាមរយៈអនុស្សរណៈនៃការយោគយល់គ្នានេះ សហរដ្ឋអាមេរិកនឹងបន្តកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការគាំទ្រដល់កម្មវិធីអាទិភាព សន្តិសុខសុខភាពសកល សម្រាប់កិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺ រួមមានជំងឺអេដស៍, ជំងឺរបេង និងជំងឺគ្រុនចាញ់ ។ បន្ថែមពីលើនេះ កិច្ចព្រមព្រៀងចែករំលែកទិន្នន័យ បានបង្កើតនូវលក្ខខណ្ឌដើម្បីធានាថាទិន្នន័យសុខាភិបាលដែលត្រូវបានប្រមូល និងចែករំលែកក្រោមកិច្ចព្រមព្រៀងនឹងត្រូវបានគ្រប់គ្រងត្រឹមត្រូវដើម្បីធានាឯកជនភាព និងសុវត្ថិភាពទិន្នន័យ ។

គោលបំណងសំខាន់នៃអនុស្សារណៈនៃការយោគយល់គ្នា គឺដើម្បីពង្រឹងបន្ថែមនូវការតាមដាន និងការឆ្លើយតបទៅនឹងការរីករាលដាលនៃជំងឺឆ្លង, បណ្ដាញមន្ទីរពិសោធន៍ និងប្រព័ន្ធទិន្នន័យ ។ អនុស្សារណៈនៃការយោគយល់គ្នានេះក៏បានរួមបញ្ចូលការពង្រឹងប្រព័ន្ធជាតិ និងសមត្ថភាពស្ថាប័នដែលស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ។ កិច្ចខិតខំប្រឹងប្រែងរួមគ្នានេះ នឹងរួមចំណែកដល់ការសម្រេចឱ្យបាននូវគោលដៅរបស់កម្ពុជា ក្នុងការលុបបំបាត់ជំងឺគ្រុនចាញ់, ការបញ្ចប់ការគំរាមកំហែងដល់សុខភាពសាធារណៈដែលបង្កឡើងដោយជំងឺអេដស៍, ការកាត់បន្ថយអត្រាឈឺ និងអត្រាមរណៈដោយសារជំងឺរបេង ព្រមទាំងការធានាឱ្យបាននូវការរកឃើញ និងការឆ្លើយតបទៅនឹងការរាតត្បាតនៃជំងឺ ។ ក្នុងរយៈពេល ៥ឆ្នាំ រដ្ឋាភិបាលសហរដ្ឋអាមេរិកគ្រោងនឹងផ្ដល់ការគាំទ្រក្នុងទំហំហិរញ្ញប្បទានប្រមាណ **៣០ លានដុល្លារអាមេរិក** និងចូលរួមដោយបដិភាគរាជរដ្ឋាភិបាលកម្ពុជា ចំនួនប្រមាណ **៥ លានដុល្លារអាមេរិក** ផងដែរ ។ ការណ៍នេះឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីការប្ដេជ្ញាចិត្តរបស់រដ្ឋាភិបាលនៃប្រទេសទាំងពីរក្នុងការពង្រឹងសមត្ថភាពកម្ពុជាដើម្បីសម្រេចបានវិស័យសុខាភិបាលដែលប្រកបដោយចីរភាព ។

អនុស្សរណៈនៃការយោគយល់គ្នា ក៏ចែងអំពីការបង្កើតគណៈកម្មាធិការដឹកនាំកិច្ចសហប្រតិបត្តិការសុខាភិបាល (Joint Health Cooperation Steering Committee) ដែលជាយន្តការសម្របសម្រួល និងត្រួតពិនិត្យដើម្បីតាមដានវឌ្ឍនភាព, តម្រង់ទិសដៅការអនុវត្ត និងពិនិត្យឡើងវិញនូវសកម្មភាពនានាជាប្រចាំ សំដៅធានាឱ្យបាននូវប្រសិទ្ធភាព និងសង្គតិភាពជាមួយនឹងគោលបំណងរួមនៃភាពជាដៃគូ ។

**លោកស្រី** **Bridgette L. Walker** ភារៈធារីនៃស្ថានទូតសហរដ្ឋអាមេរិក បានគូសបញ្ជាក់ពីសារៈសំខាន់នៃកិច្ចព្រមព្រៀងទាំងនេះ ដែលជាសក្ខីភាពឆ្លុះបញ្ចាំងពីសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការក្នុងវិស័យសុខាភិបាលអស់រយៈពេលជាង ៣០ ឆ្នាំ រវាងសហរដ្ឋអាមេរិក និងកម្ពុជា ។ យុទ្ធសាស្ត្រសុខភាពសកលអាមេរិកទីមួយ (America First Global Health Strategy) សម្រេចបាននូវវឌ្ឍនភាពឆ្ពោះទៅរកការធានានូវអនាគតមួយដែលអាចទប់ស្កាត់ការផ្ទុះឡើង និងរីករាលដាលនៃជំងឺឆ្លង ។ ការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាទ្វេភាគីលើវិស័យសុខាភិបាល គឺដើម្បីពង្រឹងប្រព័ន្ធសុខាភិបាលក្នុងស្រុកឱ្យមានភាពធន់ សំដៅលើកកម្ពស់សុខុមាលភាពប្រជាជនតាមរយៈការបង្ការការរីករាលដាលនៃជំងឺឆ្លង ។ រដ្ឋាភិបាលអាមេរិកមានមោទនភាពក្នុងការបន្តធ្វើការរួមគ្នាជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីគាំទ្រដល់ការពង្រឹងសមត្ថភាពស្ថាប័ន ក្នុងការដោះស្រាយបញ្ហាប្រឈមសុខភាពសាធារណៈនាពេលបច្ចុប្បន្ន ក៏ដូចជាការត្រៀមលក្ខណៈសម្រាប់រាល់ការគំរាមកំហែងផ្នែកសុខភាពនានា ដែលអាចនឹងកើតមានឡើងនាពេលអនាគត ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា ការអភិវឌ្ឍមូលធនមនុស្ស គឺជាអាទិភាពសំខាន់មួយក្នុងចំណោមអាទិភាពនៃកិច្ចអភិវឌ្ឍន៍កម្ពុជា ។ រាជរដ្ឋាភិបាលកម្ពុជាផ្តល់សារៈសំខាន់ និងការយកចិត្តទុកដាក់ខ្ពស់ដល់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ក្នុងការពង្រឹងប្រព័ន្ធសុខាភិបាលជាតិ និងការការពារសុខុមាលភាពរបស់ប្រជាជន សំដៅដល់ការអភិវឌ្ឍមូលធនមនុស្ស ។ ការចុះហត្ថលេខានេះ ឆ្លុះបញ្ចាំងពីស្មារតីនៃកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ រវាងកម្ពុជា និងសហរដ្ឋអាមេរិក ព្រមទាំងបញ្ជាក់ពីភាពជាអ្នកដឹកនាំរបស់កម្ពុជាក្នុងវិស័យសុខាភិបាល រួមទាំងការពង្រឹងសមត្ថភាពស្ថាប័ន និងការធានាឱ្យបាននូវសមិទ្ធផលក្នុងវិស័យសុខាភិបាលសាធារណៈប្រកបដោយចីរភាព ដើម្បីជាប្រយោជន៍ដល់ជាតិ និងប្រជាជន ។

អនុស្សរណៈនៃការយោគយល់គ្នានេះ បញ្ជាក់ពីការប្តេជ្ញាចិត្តរួមគ្នាក្នុងការរក្សានូវផលប្រយោជន៍រួមលើវិស័យសុខាភិបាល និងការការពារសុខុមាលភាពរបស់ប្រជាជន ដោយគាំទ្រដល់គោលដៅរយៈពេលវែងក្នុងការកសាងប្រព័ន្ធសុខាភិបាលដែលមានភាពធន់ និងចីរភាពក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ៕